LONG BEACH
UNIFIED SCHOOL DISTRICT

*កែសម្រួលឡើងវិញថ្ងៃទី២៧ មិនា ២០២០*

# សាលារៀនបិទទ្វាររហូតទៅដល់ថ្ងៃទី៣ខែឧសភាយ៉ាងឆាប់

ការបិទទ្វារនេះគឺដើម្បីបង្ការកាពារការឆ្លងរាលដាលនៃវីរុសកូរ៉ូណា ឬ កូវិឌ១៩ COVID-19។ ព័ត៌មាន បន្ថែមទៀតនឹងមានផ្តល់ជូនតាមរយៈគេហទំព័រក្រសួងអប់រំឡុងប៊ីចនៅ **lbschools.net** និងតាមរយៈគេហទំព័រផ្ទាល់ខ្លួនរបស់សាលារៀននីមួយៗ អ៊ីមែល សារ សារសម្លេង បណ្តាញសង្គម និងតាមរយៈ អនឡាញវីដេអូ នាថ្ងៃនិងសប្តាហ៍ខាងមុខនេះ។

# ការចែកអាហារសម្រាប់យកទៅញុំានៅផ្ទះ

- **ពីម៉ោង 11:30 ព្រឹកទៅដល់ 12:30 ថ្ងៃ** ពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ
- មានចែកអាហារថ្ងៃត្រង់និងអាហារពេលព្រឹកទុកសម្រាប់ថ្ងៃស្អែក

ចាប់ពីថ្ងៃទី៣០មិនាទៅ ក្រសួងអប់រំ LBUSD នឹងផ្តល់អាហារសម្រាប់យកទៅញុំានៅផ្ទះដល់កុមារអាយុមួយឆ្នាំដល់ ១៨ឆ្នាំនៅ ក្នុងរយៈពេលដែលសាលាបិទទ្វារ នៅសាលា: Addams, Avalon, Birney, Bixby, Burbank, Chavez, Dooley, Emerson, Gant, Garfield, Gompers, Grant, Harte, Henry, Herrera, King, Lafayette, Lincoln, Lindbergh, Longfellow, MacArthur, Marshall, McKinley, Muir, Riley, Rogers, Roosevelt, Signal Hill, Smith, Stevenson, Twain, Washington, Whittier and Willard.

រកមើលផែនទីសាលារៀនដោយចូលទៅគេហទំព័រក្រសួងអប់រំនៅ lbschools.net រួចចុច ABOUT > Map
អាហារនេះផ្តល់ឱ្យដោយមិនគិតតម្លៃដល់សិស្សទាំងអស់ មិនថាឡើយសិស្សទៅរៀននៅសាលារៀនណាមួយក៏ដោយ ហើយមិនចាំបាច់បង្ហាញក្រដាសស្នាមអ្វីទេ។ សិស្សត្រូវតែមានវត្តមានមកយកអាហារដោយខ្លួនឯង។

# ឱកាសសិក្សានៅផ្ទះ

នៅក្នុងរយៈពេលដែលសាលាបិទទ្វារនេះ សិស្សនិងមាតាបិតាអាចប្រើគេហទំព័រឱកាសសិក្សានៅផ្ទះ នៅ **lbschools.net** ដើម្បីរកមើលធនធានផ្សេងៗប្រចាំសាលារៀននិងគ្រូបង្រៀននីមួយៗ។

LONG BEACH UNIFIED SCHOOL DISTRICT
Home Learning
OPPORTUNITIES